ដើម្បីកុមារគ្រប់រូប

*សេចក្តីប្រកាសព័ត៌មាន*

## កម្ពុជាដាក់ឱ្យដំណើរការយុទ្ធនាការជាតិដើម្បីលើកកម្ពស់ការគាំពារ និងអភិវឌ្ឍន៍កុមារតូច និងការអប់រំកម្រិតមូលដ្ឋាន

ខេត្តកំពង់ចាម ថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២៥ – ខណៈដែលកម្ពុជាត្រៀមបើកថ្នាក់រៀនសម្រាប់ឆ្នាំ សិក្សា ២០២៥-២០២៦ នៅខែវិច្ឆិកាខាងមុខនេះ។ ក្រសួងអប់រំ យុវជន និងកីឡា គាំទ្រដោយយូនីសេហ្វ កំពុង ធ្វើយុទ្ធនាការទូទាំងប្រទេស ដើម្បីដោះស្រាយបញ្ហាអត្រាបោះបង់ការសិក្សាដែលនៅតែខ្ពស់នៅឡើយ និងធានាថា កុមារគ្រប់រូបចាប់ពីវ័យកុមារតូច រហូតដល់វ័យជំទង់ទទួលបានការអប់រំប្រកបដោយបរិយាប័ន្ន និងគុណភាព។

ប្រទេសកម្ពុជា បានសម្រេចនូវវឌ្ឍនភាពក្នុងវិស័យអប់រំគួរឱ្យកត់សម្គាល់កំឡុងពេលប៉ុន្មានឆ្នាំកន្លងមក។ កុមារបានចុះឈ្មោះចូលរៀនកំពុងមានការកើនឡើងជាបន្តបន្ទាប់ ហើយកំពុងរស់រានមានជីវិតនៅក្នុងឆ្នាំដំបូងនៃជីវិតរបស់ពួកគេ។ ទោះយ៉ាងណាក៏ដោយ កុមារ និងក្មេងជំទង់ជាច្រើននៅតែមិនបានចូលរៀន។

ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ ជួនណារ៉ុន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា បានមានប្រសាសន៍ថា "ការធ្វើឲ្យប្រសើរឡើងនូវលទ្ធផលសិក្សា និងការកាត់បន្ថយការបោះបង់ការសិក្សារបស់កុមារនៅតែជាអាទិភាពចម្បងនៃផែនការយុទ្ធសាស្ត្រវិស័យអប់រំរបស់យើង។ ខណៈពេលដែលកម្ពុជា បានពង្រីកលទ្ធភាពនៃការទទួលបានសេវាអប់រំគ្រប់កម្រិតមានការរីកចម្រើនគួរឱ្យកត់សម្គាល់ មិនត្រឹមតែប៉ុណ្ណោះយើងត្រូវធានាថា កុមារគ្រប់រូបមិនត្រឹមតែបានចូលសាលារៀនប៉ុណ្ណោះទេ ប៉ុន្តែពួកគេត្រូវបញ្ចប់ការសិក្សាដោយមានជំនាញចាំបាច់សម្រាប់ជីវិត និងការងារផងដែរ។ ក្រសួងអប់រំ យុវជន និងកីឡា សហការជាមួយយូនីសេហ្វ និងដៃគូរបស់យើង កំពុងចាប់ផ្តើមយុទ្ធនាការដើម្បីពង្រឹងការគាំពារ និងអភិវឌ្ឍកុមារតូច លើកកម្ពស់ការរៀនសូត្រប្រកបដោយបរិយាប័ន្ន និងដោះស្រាយបញ្ហាប្រឈមនានាដែលនាំអោយកុមារបោះបង់ការសិក្សា។ យើងកំពុងធ្វើការរួមគ្នាដើម្បីកសាងប្រព័ន្ធអប់រំ ដែលមានសមធម៌ មានភាពធន់ និងឆ្លើយតបទៅនឹងតម្រូវការរបស់អ្នកសិក្សាគ្រប់រូបនៅទូទាំងប្រទេសកម្ពុជា"។

នៅក្នុងឆ្នាំ២០២៣ កម្ពុជាមានកុមារក្នុងវ័យសិក្សាប្រមាណ ៣ លាននាក់ (២ លាននាក់នៅក្នុងបឋមសិក្សា និង ១ លាននាក់នៅអនុវិទ្យាល័យ) ដែលក្នុងនោះមានកុមារនិងក្មេងជំទង់ប្រហែល៣សែននាក់គឺនៅក្រៅសាលា[1]។ គិតមកដល់ឆ្នាំ២០២៤ អត្រាបោះបង់ការសិក្សានៅតែខ្ពស់គឺមានកុមារ ១៥.៥ ភាគរយបានបោះបង់ការសិក្សានៅកម្រិតមធ្យមសិក្សាបឋមភូមិ។ លើសពីនេះមានកុមារអាយុពី ៣ ដល់ ៥ឆ្នាំ តែ៤៣ភាគរយប៉ុណ្ណោះ ដែលបានចុះឈ្មោះចូលរៀននៅសាលាមត្តេយ្យសិក្សា[2]។ ខណៈពេលដែលក្មេងជំទង់កាន់តែច្រើនកំពុងនៅរៀន មានតែ ៦០ ប៉ុណ្ណោះភាគរយ បានបញ្ចប់អនុវិទ្យាល័យ[3]។ ប៉ុន្តែទិន្នន័យចុងក្រោយរបស់ក្រសួងអប់រំ យុវជន និងកីឡា បានបង្ហាញថា កុមារអាយុ ៥ឆ្នាំ ប្រមាណ ៣០% មិនទាន់បានចុះឈ្មោះចូលរៀននៅកម្រិតកុមារតូចបានគ្រប់ៗគ្នានៅឡើយ។

"ការអប់រំប្រកបដោយគុណភាពមិនមែនជាក្តីសុបិន្តទេ វាគឺជាកាតព្វកិច្ច។ អនាគតរបស់កូនចៅរបស់យើងមិនអាចរង់ចាំបានទេ" លោកបណ្ឌិត វីល ផាកស៍ នាយកយូនីសេហ្វប្រចាំនៅកម្ពុជាបានថ្លែងនៅក្នុងពិធីប្រកាសដាក់ឲ្យអនុវត្តជាផ្លូវការនៅខេត្តកំពង់ចាម។ "យើងត្រូវតែធ្វើសកម្មភាពឥឡូវនេះ ដើម្បីធានាថា កុមារគ្រប់រូបត្រូវបានមើលឃើញ គាំទ្រ និងផ្ត

[1] វិទ្យាស្ថាន UNESCO សម្រាប់ស្ថិតិឆ្នាំ២០២៣
[2] របាយការណ៍សន្និបាតអប់រំឆ្នាំ២០២៥
[3] របាយការណ៍សន្និបាតអប់រំឆ្នាំ២០២៥

ល់ឱកាសដោយស្មើគ្នា។ ទាំងនេះជាមូលហេតុ ដែលយើងគាំទ្រក្រសួងអប់រំ យុវជន និងកីឡា ក្នុងការចាប់ផ្តើមយុទ្ធនាការសាធារណៈចំនួនពីរ រួមគ្នាដោយគោលដៅតែមួយគឺ ធានាបាននូវការអប់រំប្រកបដោយគុណភាពសម្រាប់កុមារគ្រប់រូប ចាប់ពីវ័យកុមារតូចរហូតដល់វ័យជំទង់"។

កុមារមកពីគ្រួសារក្រីក្រ តំបន់ជនបទ សហគមន៍ជនជាតិដើមភាគតិច និងកុមារដែលមានពិការភាពបន្តប្រឈមនឹងឧបសគ្គក្នុងការរៀនសូត្រ និងមានចំនួនតិចតួចក្នុងថ្នាក់រៀន។ កុមារដែលមានពិការភាពទំនងជាមិនបានចូលរៀនរហូតដល់ទៅពីរដង បើធៀបជាមួយកុមារដទៃដែលមានអាយុប្រហាក់ប្រហែលគ្នា ។

យុទ្ធនាការរួមគ្នានេះមានគោលបំណងលើកកម្ពស់ការយល់ដឹង កៀរគរសហគមន៍ និងពង្រឹងប្រព័ន្ធគាំទ្រដើម្បីរក្សាកុមារឲ្យនៅបន្តសិក្សា និងបង្កើនលទ្ធផលសិក្សា។ យុទ្ធនាការនេះនឹងផ្តោតលើការអប់រំកុមារតូច បរិយាកាសសិក្សាប្រកដោយបរិយាប័ន្ន និងអន្តរាគមន៍តាមតម្រូវការ សម្រាប់កុមារដែលងាយរងគ្រោះបំផុត។ យុទ្ធនាការនេះរួមមានសមាសធាតុសំខាន់ពីរ៖

- ឪពុកម្តាយខ្នះខ្នែង កូនឆ្លាត គឺជាយុទ្ធនាការផ្តោតលើ ការគាំពារ និងអភិវឌ្ឍន៍កុមារតូច ដែលគាំទ្រអ្នកថែទាំក្នុងការត្រៀមកុមារចូលរៀន តាមរយៈការតាមដានការលូតលាស់ ការលេង អាហារូបត្ថម្ភ និងការចុះឈ្មោះចូលរៀននៅមត្តេយ្យសិក្សា។
- ជម្រើសអ្នក អនាគតអ្នក គឺជាយុទ្ធនាការដើម្បីទប់ស្កាត់ការបោះបង់ការសិក្សារបស់កុមារវ័យជំទង់ លើកទឹកចិត្តពួកគេឱ្យនៅសិក្សា និងស្វែងរកការគាំទ្រដោយឆ្លើយតបទៅនឹងសម្ពាធផ្សេងៗ ដូចជា ការរៀបការវ័យក្មេង ពលកម្មកុមារ និងកង្វះការលើកទឹកចិត្ត។

យុទ្ធនាការនេះនឹងចាប់ផ្តើមនៅក្នុងខេត្តរតនគិរី សៀមរាប និងកំពង់ចាម ដែលជាខេត្តមានអត្រាបោះបង់ការសិក្សាខ្ពស់ និងមានវិសមភាពខ្លាំង។ ដើម្បីគាំទ្រយុទ្ធនាការនេះ យូនីសេហ្វ និងក្រសួងអប់រំ យុវជន និងកីឡា កំពុងផ្តល់ឲ្យនូវឧបករណ៍ដែលងាយស្រួលអនុវត្តទៅដល់គ្រួសារ សាលារៀន សហគមន៍ ដែលរួមមានទាំងវីដេអូ សារជាសំឡេង ឯកសារដែលបានបោះពុម្ព និងសម្ភារៈជាអន្តរកម្មផ្សេងៗ។ សម្ភារៈទាំងនេះមាននៅលើអ៊ីនធឺណិតតាមតំណភ្ជាប់: https://unicef.link/46QraSN

យុទ្ធនាការនេះនឹងត្រូវបានអនុវត្តនៅទូទាំងប្រទេស តាមរយៈបណ្តាញពហុព័ត៌មាន រួមទាំងប្រព័ន្ធបណ្តាញសង្គម វិទ្យុ ទូរទស្សន៍ និងការទៅផ្សព្វផ្សាយដល់សហគមន៍។ ក្រសួងអប់រំ យុវជន និងកីឡា និងយូនីសេហ្វ លើកទឹកចិត្តដល់ដៃគូរអភិវឌ្ឍ រាជរដ្ឋាភិបាល អង្គការសង្គមស៊ីវិល និងអង្គភាពពត៌មានទាំងអស់ ឱ្យផ្សព្វផ្សាយ និងអនុវត្តយុទ្ធនាការនេះយ៉ាងសកម្មនៅក្នុងខេត្តរៀងៗខ្លួន ដើម្បីធានាថាកុមារទាំងអស់នៅកម្ពុជា ជាពិសេសកុមារដែលងាយរងគ្រោះបំផុតទទួលបានអត្ថប្រយោជន៍ពីអន្តរាគមន៍ទាំងអស់នេះ។

###

អំពីយូនីសេហ្វ

យូនីសេហ្វធ្វើការងារនៅតាមទីកន្លែងលំបាកបំផុតមួយចំនួននៅក្នុងពិភពលោក ដើម្បីគាំទ្រដល់កុមារដែលស្ថិតក្នុងស្ថានភាពលំបាកបំផុត។ នៅក្នុងប្រទេស និងដែនដីចំនួនជាង ១៩០ យើងធ្វើការងារដើម្បីកុមារគ្រប់រូបនៅគ្រប់ទីកន្លែង ដើម្បីកសាងពិភពលោកមួយកាន់តែល្អសម្រាប់មនុស្សគ្រប់រូប។

សម្រាប់ព័ត៌មានបន្ថែមអំពីអង្គការយូនីសេហ្វ និងការងាររបស់ខ្លួននៅកម្ពុជា សូមចូលទៅកាន់គេហទំព័រ៖ www.unicef.org.kh

តាមដានយូនីសេហ្វនៅកម្ពុជាតាមរយៈ៖ Facebook | Twitter | យូធូប | Instagram | LinkedIn | Threads | TikTok

សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនង៖

លោក Hadrien Bonnaud
ប្រធានផ្នែកទំនាក់ទំនង យូនីសេហ្វប្រចាំកម្ពុជា
ទូរសព្ទ៖ +855 23 260 204, អ៊ីមែល៖ hbonnaud@unicef.org

លោក ចាន់ ទី
មន្ត្រីឯកទេសផ្នែកទំនាក់ទំនង យូនីសេហ្វប្រចាំកម្ពុជា
ទូរសព្ទ៖ +855 23 260 204, អ៊ីមែល៖ tchan@unicef.org